00159507

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

D/A61

**Declassified to Public**
**06 September 2012**

# ការិយាល័យរបស់សហចៅក្រមស៊ើបអង្កេត

# អនុស្សារណៈអន្តរការិយាល័យ

ចំពោះ សាស្ត្រាចារ្យ បិន ឃៀរណិន

ថ្ងៃទី: ២២/០១/២០០៨

A: **Benedict F. Kiernan**
Director, Genocide Studies Program
Hall of Graduate Studies
Department of History
320 York Street
New Haven, CT 06511, USA
Email: ben.kiernan@yale.edu

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 25 / 01 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA
Ref:

THROUGH:
PAR:

FROM:
DE:
យូ ប៊ុនឡេង
ម៉ារសែល ឡឺម៉ុងដឺ
សហចៅក្រមស៊ើបអង្កេត

ECCC * C.E.T.C. * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

SUBJECT:
OBJET: ការផ្តល់ឯកសារទាក់ទងសំណុំរឿងលេខ 001/18-07-2007-ECCC-OCIJ (កាំង ហ្គិច អ៊ាវ ហៅ ឌុច) និង 002/19-09-2007-ECCC-OCIJ ( នួន ជា ខៀវ សំផន អៀង សារី និង អៀង ធិរិទ្ធ)

ORIGINAL DOCUMENT
RECEIVED ON 25-01-2008
AT: 11:45
BY SANN RADA
COURT OFFICER

លោក សាស្ត្រាចារ្យ បិន ឃៀរណិន

យើងធ្វើការយោងទៅលើការស៊ើបអង្កេតរបស់យើងដែលបានធ្វើឡើងនាពេលបច្ចុប្បន្នដែលពាក់ព័ន្ធទៅនឹងការចោទប្រកាន់ប្រឆាំងនឹងមនុស្សប្រាំនាក់ដែលមាននៅក្នុងសំណុំរឿងនៃការស៊ើបអង្កេតពីរផ្សេងគ្នាដូចបានចង្អុលបង្ហាញខាងលើ ។

ដូចដែលលោកបានដឹងហើយថា នៅក្នុងរយៈពេលនៃការស៊ើបអង្កេតទាំងនោះ វា គឺមុខងាររបស់យើងក្នុងការប្រមូលនូវភ័ស្តុតាង ឯកសារនិងសំភារៈផ្សេងទៀតដែលពាក់ព័ន្ធ ទោះបីជាច្បាប់ថតចម្លង ឬ ជាច្បាប់ដើម

ក៏ដោយ។ មធ្យោបាយចំបងក្នុងការធ្វើការងារនេះ គឺការចេញដីកាចាត់ឱ្យស៊ើបសួរជំនួស ដែលផ្តល់សិទ្ធអំណាចដល់ក្រុមការងារ (ជាទូទៅ គឺក្រុមអ្នកស៊ើបអង្កេតនៃការិយាល័យរបស់យើង) ដើម្បីស្វែងរកនិងបញ្ជូនមកឱ្យយើងនូវភ័ស្តុតាងជាសំភារៈផ្សេងៗ ហើយ វាក៏បង្កើតឱ្យមានជាកាតព្វកិច្ចមួយចំពោះសាម៉ីជនណាម្នាក់ឱ្យផ្តល់មកឱ្យយើងនូវសំភារៈទាំងឡាយដែលមានចង្អុលបង្ហាញនៅក្នុងដីការចាត់ឱ្យស៊ើបសួរជំនួសនោះ។ វាគឺជាចំនុចចាប់ផ្តើមដ៏ចាំបាច់មួយ ដើម្បីឱ្យយើងអាចមានលទ្ធភាពក្នុងការដាក់ភ័ស្តុតាងជាសម្ភារៈទៅក្នុងសំណុំរឿងជាផ្លូវការ។

មុននឹងធ្វើការចេញដីកាចាត់ឱ្យស៊ើបសួរជំនួសណាមួយ និង ដើម្បីជួយយើងក្នុងការធ្វើការសំរេចអំពីវិធីដែលល្អប្រសើរបំផុតក្នុងចំណាត់ការនោះ យើង សូមអរគុណទុកជាមុន បើសិនជាលោកបង្ហាញប្រាប់យើងអំពីប្រភេទនៃភ័ស្តុតាងជាសម្ភារៈទាំងឡាយដែលកំពុងស្ថិតនៅក្រោមការកាន់កាប់ ឬ ការគ្រប់គ្រងរបស់លោក ទោះបីភ័ស្តុតាងទាំងនេះជាច្បាប់ថតចម្លង ឬ ក៏ជាច្បាប់ដើមក៏ដោយ រួមទាំងទីតាំងនៃភ័ស្តុតាងសំភារៈទាំងនេះផងដែរ។